# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ជ
ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា
ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 03-Sep-2012, 15:14
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះ
អាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

**សំណើតាមវិធាន ៨៧ សុំប្រើប្រាស់ឯកសារក្នុងអំឡុងពេលសួរដេញដោលសាក្សី**
PHILIP SHORT

---

ដាក់ដោយ៖

**ក្រុមមេធាវីការពារក្តី នួន ជា**
សុន អរុណ
Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW
ព្រំ ផល្លា
Scarlett WANGER
Devika KAMP

ផ្ញើជូន៖

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Andrew CAYLEY
**ក្រុមមេធាវីការពារក្តីទាំងអស់**

១. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("វិធានផ្ទៃក្នុង")[1] មេធាវីការពារក្តីជនជាប់ចោទ នួន ជា ("ក្រុមមេធាវីការពារក្តី") តទៅនេះ សូមដាក់សំណើ ("សំណើ") សុំប្រើប្រាស់ឯកសារខាងក្រោមក្នុងអំឡុងពេលសួរដេញដោល សាក្សីអ្នកជំនាញ Philip Short (ឯកសារ):

ក. Blythe Yee, 'Navigating Darkness (ការបើកបរក្នុងភាពខ្មៅងងឹត)', Asian Wall Street Journal, ចុះថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០០៥ ។

ខ. 'Charlie Rose' (ប្រតិចារិតនៃការសម្ភាសន៍) ថ្ងៃទី ២៩ ខែ មិនា ឆ្នាំ ២០០៥ ។

គ. Brendan Brady, "កម្ពុជាប្រឈមនឹងពាក្យ G 'Cambodia Confronts the 'G' Word', Foreign Policy, ថ្ងៃទី ៨ ខែ មករា ឆ្នាំ ២០១០ ។

ឃ. "អតីតមេខ្មែរក្រហម ត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍" Press TV, ផ្សាយថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩ ។

២. ពហុក្រុមមេធាវីការពារក្តី និងសហព្រះរាជអាជ្ញាបានកត់សម្គាល់ថា ភាគីមិនអាចដាក់បញ្ចូល "កំណត់ហេតុ ប្រវត្តិរូប ឬ ការអធិប្បាយដោយសាក្សីនិមួយៗបានទេ ដរាបណាបញ្ជីឈ្មោះ សាក្សីរបស់អង្គជំនុំជម្រះសាលាដំបូង មិនទាន់បានបង្កើតនៅឡើយ ហើយការស្តាប់សក្ខីរបស់ សាក្សីក៏មិនទាន់បានកំណត់កាលបរិច្ឆេទស្តាប់នៅឡើយដែរ។ ដោយសារធនធានមានកម្រិត... ភាគីមិនអាចរៀបចំឲ្យបានពេញលេញសម្រាប់ការតាំងសំណួរដល់សាក្សីដែលបានស្នើឡើង

---

[1] ដូចដែលមេធាវីការពារក្តីបានលើកអំណះអំណាងជាច្រើនដងរួចមកហើយថា ខ្លួនមានសិទ្ធិប្រើប្រាស់ឯកសារណាមួយ ដែលពាក់ព័ន្ធសម្រាប់គោលបំណងជជីកសួរដេញដោលពីភាពអាចជឿទុកបាននៃសាក្សី ។ ពុំមានការដាក់កំហិតនៅក្នុង វិធាន ផ្ទៃក្នុងឬក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនឲ្យមេធាវីការពារក្តីប្រើប្រាស់កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការ ស្តាប់ចម្លើយសាក្សីក្នុងអំឡុងពេលសួរដេញដោលសាក្សីឡើយ។ ហេតុដូច្នេះមេធាវីការពារក្តីមានសិទ្ធិប្រើប្រាស់ឯកសារ ដោយសារគោលបំណងដែលមានកម្រិតនោះ។ សូមមើលឯកសារ E-206 "សេចក្តីជូនដំណឹងអំពីការដាក់ឯកសារសម្រាប់ ជជីកសួរដេញដោលសាក្សីអ្នកជំនាញ TCW-487 ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១២ ERN 00811080-00811083, នៅ កថាខណ្ឌ១ ដល់២។ ឯកសារ E-206.2 "ឧបសម្ព័ន្ធខ: សំណោះលើកមុនរបស់មេធាវីការពារក្តីសុំដាក់ឯកសារសម្រាប់ ជជីកសួរដេញដោលសាក្សីចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១២ ERN 00812802-00812805 ។

ទាំងអស់នោះបានឡើយ រហូតដល់ការកំណត់ពេលវេលាសម្រាប់ស្តាប់សក្ខីកម្មរបស់សាក្សីចូលជាធរមាន[2]។ អង្គជំនុំជម្រះហាក់ដូចជាបានយល់ស្របនឹងការយល់ឃើញបែបនោះ ដោយបានទទួលយកជាភស្តុតាងនូវឯកសារនានា ដែលអាចរកបាននៅមុនការជំនុំជម្រះ បើសិនជាឯកសារ ត្រូវបានដាក់ជាមួយនឹងការជូនដំណឹងគ្រប់គ្រាន់នៅមុនការកំណត់ពេលវេលាស្តាប់សក្ខីកម្មរបស់សាក្សី និងពុំបង្កការអន្តរាយដល់ភាគីដទៃ[3]។ តាមពិតអង្គជំនុំជម្រះបានទទួលយកជាភស្តុតាងនូវឯកសារដែលដាក់ដោយសហព្រះរាជអាជ្ញា បើទោះជាពុំមានកិច្ចប្រឹងប្រែងណាមួយ ដើម្បីបំពេញតាមវិធាន ៨៧(៤) ដោយឈរលើមូលដ្ឋានដែលថាឯកសារទាំងនោះ ជាការថ្លែងរបស់បុគ្គលទាំងឡាយ ដែលនឹងចូលខ្លួនផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[4]។

៣. ឯកសារនីមួយៗរួមមានការសម្ភាសន៍ ឬសេចក្តីថ្លែងការណ៍របស់លោក Short ទាក់នឹងប្រធានបទនានាដែលជាបញ្ហានៅចំពោះមុខអង្គជំនុំជម្រះ។ ឯកសារទាំងនេះមិនបានលើកឡើងនូវអង្គហេតុថ្មី ឬបញ្ហាផ្នែកច្បាប់ ដែលតម្រូវឲ្យមានការស៊ើបអង្កេតដោយភាគី ហើយនឹងធ្វើឲ្យនឹកឃើញឡើងវិញនូវ ឬ ការជំទាស់ទៅនឹងសក្ខីកម្មរបស់សាក្សីតែប៉ុណ្ណោះ។ ការទទួល

---

[2] ឯកសារ E-216 "សំណើអនុលោមតាមវិធាន៨៧(៤) របស់សហព្រះរាជអាជ្ញា សុំដាក់ឯកសារបីដែលនិពន្ធដោយសាក្សី TCW 694 ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១២ ERN 00823196 – 00823202 នៅកថាខណ្ឌទី៨(គ)។ សូមមើលផងដែរ ឯកសារ E-172/24/3 "សំណើអនុលោមតាមវិធាន៨៧(៤) របស់ អៀង សារី ទាក់ទងនឹងឯកសារដែលត្រូវប្រើប្រាស់ក្នុងអំឡុងពេលជជីកសួរដេញដោលអ្នកជំនាញ Professor David Chandler ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១២ ERN 00815937-00815941 នៅកថាខណ្ឌទី៦ដល់៨ ។ ឯកសារ E-172/27/1 "សំណើអនុលោមតាមវិធាន៨៧(៤) ទាក់ទងនឹងឯកសារដែលត្រូវប្រើប្រាស់ក្នុងអំឡុងពេលជជីកសួរដេញដោលអ្នកជំនាញ Professor David Chandler ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១២ ERN 00823751-00823756, នៅកថាខណ្ឌទី១៤-១៦។

[3] ឯកសារ E-តបាន172/24/4 "អនុស្សរណរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំផ្តល់ឯកសារនៅក្នុងសំណុំរឿង ទៅឲ្យអ្នកជំនាញ និងសំណើរបស់ អៀង សារី ដោយអនុលោមតាមវិធាន ៨៧(៤) ទាក់ទងនឹងឯកសារដែលត្រូវប្រើប្រាស់ក្នុងអំឡុងពេលសួរដេញដោលអ្នកជំនាញ David Chandler (E172/24/2 and E172/24/3) ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២ ERN 00818308-00818309 នៅកថាខណ្ឌទី៨។

[4] ឯកសារ E-190 "សេចក្តីសម្រេចទាក់ទងនឹងឯកសារថ្មី និងបញ្ហាទាក់ព័ន្ធដទៃទៀត" ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២ ERN 00804367-00804382 នៅកថាខណ្ឌទី៣៩ ។

យកនូវឯកសារទាំងនេះនឹងមិនបង្កការអន្តរាយដល់ភាគីណាមួយឡើយ។ ដោយសារលោក Short នឹងត្រូវចូលខ្លួនផ្តល់សក្ខីកម្មនៅថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១២[5] សំណើនេះបំពេញបានលក្ខខណ្ឌនៃការជូនដំណឹងពីរសប្តាហ៍ជាមុន ដែលតម្រូវដោយអង្គជំនុំជម្រះ[6] និងផ្តល់ពេលវេលានៃការជូនដំណឹងស្រដៀងគ្នានេះដល់សំណើបែបនេះដទៃ ត្រូវបានអនុញ្ញាតពីលើកមុនដល់ភាគីដទៃ[7]។ ផ្នែកដែលពាក់ព័ន្ធ ត្រូវបានបកប្រែជាភាសាខ្មែរ និងបារាំង និងដាក់ភ្ជាប់មកជាមួយអត្ថបទដើមភាសាអង់គ្លេស។

៤. ឯកសារទាំងនេះក៏បំពេញបានការវាយតម្លៃផ្អែកលើភស្តុតាង ដែលមានចែងនៅក្នុងវិធាន៨៧(៣) និបានដាក់បញ្ចូលនៅក្នុង ៨៧(៤)។ ភស្តុតាងទាំងបួននេះ គឺពាក់ព័ន្ធ។ ឯកសារ **ក** មានកំណត់ហេតុទាក់ទងនឹងវិធីសាស្ត្រស្រាវជ្រាវរបស់លោក Short ដែលផ្តល់នូវភាពអាចជឿទុកចិត្ត និងតម្លៃដែលអាចបង្ហាញផ្លូវនៃសក្ខីកម្មរបស់គាត់។ ឯកសារ **ខ គ និងឃ** មានកំណត់ហេតុនានាទាក់ទងនឹងទស្សនរបស់លោក Short អំពីគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យនៃការចាត់ទុកជាមុខសញ្ញាក្រុមជនជាតិភាគតិច ដែលនាំឲ្យមានទំនោរទទួលខុសត្រូវរបស់ជនជាប់ចោទចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការធ្វើទុក្ខបុកម្នេញ និងឧក្រិដ្ឋកម្មដទៃទៀតដែលគាត់ត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង០០២[8]។ ឯកសារ **ខ** មានកំណត់

---

[5] ឯកសារ **E-172/24**, អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង "ព័ត៌មានបច្ចុប្បន្នភាពទាក់ទិននិងការកំណត់កាលបរិច្ឆេទស្តាប់សក្ខីកម្មអ្នកជំនាញដែលភាគីបានស្នើសុំ" ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១២, ERN 00810603 ។

[6] ឯកសារ **E-218** "អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការបន្ថែមដើម្បីលើកកម្ពស់ប្រសិទ្ធភាពសវនាការ" ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០១២ ERN 00831321-00831326 នៅកថាខណ្ឌ២២។

[7] ឯកសារ **E-172/24/4** "អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំផ្តល់ឯកសារនៅក្នុងសំណុំរឿង ទៅឲ្យអ្នកជំនាញ និងសំណើរបស់ អៀង សារី ដោយអនុលោម តាមវិធាន ៨៧(៤) ទាក់ទងនឹងឯកសារដែលត្រូវប្រើប្រាស់ក្នុងអំឡុងពេលសួរដេញដោលអ្នកជំនាញ David Chandler (**E172/24/2** and **E172/24/3**) ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២ ERN 00818308-00818309 នៅកថាខណ្ឌទី៨ (ការអនុញ្ញាតលើសំណើដែលដាក់មួយខែនៅមុនការស្តាប់សក្ខីកម្មរបស់សាក្សី)។

[8] សហព្រះរាជអាជ្ញាបន្ថែមបទល្មើសការធ្វើទុក្ខបុកម្នេញនៅសវនាការវគ្គទី១នៃសំណុំរឿង ០០២/០១។ សូមមើល ឯកសារ **E-124/7.2** "ឧបសម្ព័ន្ធ: បញ្ជីនៃកថាខណ្ឌ និងផ្នែកនៃដីកាដំណោះស្រាយដែលពាក់ព័ន្ធទៅនឹងសវនាការវគ្គ១នៅក្នុងសំណុំ

ហេតុទាក់ទងនឹងការទទួលខុសត្រូវរបស់មន្ត្រីនានានៅក្រោមបង្គាប់ជនជាប់ចោទ ដែលមានទំនោរទទួលខុសត្រូវស្រដៀងគ្នាទៅនឹងកម្រិតនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ដែរ។

៥. សម្រាប់មូលហេតុស្រដៀងគ្នានេះ ឯកសារទាំងនេះមិនមែនជាឯកសារមិនសំខាន់ ឬមានបំណង ពន្យាដំណើរការនីតិវិធីនោះទេ ហើយវាបង្កើតបានជាភស្តុតាងសមស្របនៃអង្គហេតុដែលចង់បង្ហាញ(ជាពិសេសនូវអ្វីដែលសាក្សីបាននិយាយពីមុនៗ)។ ពុំមានមូលហេតុអ្វីថាឯកសារនេះ មិនត្រូវបានអនុញ្ញាតដោយច្បាប់ឡើយ ។

៦. មេធាវីការពារក្តីស្នើសុំដាក់ឯកសារទាំងនេះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងប្រើប្រាស់វាក្នុងអំឡុងពេលសួរដេញដោលលោក Philip Short ។

**សហមេធាវីការពារក្តីលោក នួន ជា**

Michiel PESTMAN | Andrew IANUZZI | Jasper PAUW

---

រឿង០០២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ ERN 00754117-00754119, ចំណុច ៤(iii) ។ សូមមើលផងដែរឯកសារ **D427**, "ដីកាដំណោះស្រាយ" ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ERN 00604508-00605246, នៅកថាខណ្ឌ១៤១៥ (ប្រជាជនត្រូវបានចាត់ទុកជាមុខសញ្ញា ដោយសារពួកគេជាសមាជិកពិតប្រាកដ ឬដោយសន្មតរបស់ក្រុមមនុស្សទាំងឡាយណាដែលត្រូវបានកំណត់ដោយអាជ្ញាធរនៃបក្សកុម្មុយនីស្តកម្ពុជា ដោយផ្អែកលើមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា)។